# II- ទីស្តីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

*រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

### អនុក្រឹត្យលេខ ១០ អនក្រ
### ស្តីពីការបង្កើត ខុទ្ទកាល័យ ស៊ីវិល ខុទ្ទកាល័យ
### យោធា និងនាយកដ្ឋាន ចំណុះក្រសួងការពារជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

### សំរេច

**មាត្រា ១ :** ត្រូវបានបង្កើតនូវស្ថាប័នដូចខាងក្រោម ដែលស្ថិតនៅក្រោមការគ្រប់គ្រងបញ្ជាផ្ទាល់របស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ គឺ :

.ខុទ្ទកាល័យ ស៊ីវិល

.ខុទ្ទកាល័យ យោធា

.នាយកដ្ឋាន សោធននិវត្តន៍

.នាយកដ្ឋានផ្គត់ផ្គង់

www.pheakdeylaw.com

.នាយកដ្ឋាន វិស្វកម្ម

.នាយកដ្ឋានប្រេងឥន្ធនៈ

.នាយកដ្ឋានបញ្ជូនសារ

.នាយកដ្ឋានសុខាភិបាល

.នាយកដ្ឋាន បសុពេទ្យ

**មាត្រា ២ :** ស្ថាប័នដែលចែងខាងលើនេះ កើតឡើងដោយការកែសំរួលរចនាសម្ព័ន្ធ ខុទ្ទកាល័យ នាយកដ្ឋានកិច្ចការយោធា ស៊ីវិល និងនាយកដ្ឋាន ភស្តុភារ របស់ក្រសួង ។

**មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ និងក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខា តទៅ ។**

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

www.pheakdeylaw.com

## រចនាសម្ព័ន្ធក្រសួងការពារជាតិ




www.pheakdeylaw.com